ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០៣៤/២១.............អអរ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

ព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ-សង្កាត់ និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តស្ទឹងត្រែង»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ឈាង ឡាក់ ប្រធានក្រុមប្រឹក្សាខេត្តស្ទឹងត្រែង**
- **ឯកឧត្តម ជួង ពៅ អភិបាលរងខេត្តស្ទឹងត្រែង**
- **លោក សាយ កុសល អភិបាលក្រុងស្ទឹងត្រែង**
- **លោក ម៉ែន គុង នាយករងរដ្ឋបាល និងជាអ្នកនាំពាក្យសាលាខេត្តស្ទឹងត្រែង**
- **លោក ជា មណ្ណា ចៅសង្កាត់ស្ទឹងត្រែង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

### I. សេចក្តីផ្តើម

ខេត្តស្ទឹងត្រែង ស្ថិតនៅភាគឦសាននៃប្រទេស មានចម្ងាយ ៤៥៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ មានព្រំប្រទល់ខាងជើងជាប់ខេត្តចាំប៉ាសាក់ និងខេត្តអត្តពឺនៃប្រទេសឡាវ ខាងកើតជាប់ខេត្តរតនគិរី ខាងត្បូងជាប់ខេត្តក្រចេះ និងខេត្តមណ្ឌលគិរី ខាងលិចជាប់នឹងខេត្តព្រះវិហារ និងខេត្តកំពង់ធំ។ ខេត្តមានផ្ទៃដី ១២.០១៦គីឡូម៉ែត្រការ៉េ ចែកជា ៦ក្រុង ស្រុក ៣៤ឃុំ សង្កាត់ ១២៨ភូមិ បច្ចុប្បន្នខេត្តមានប្រជាជន ១៦៤.៥៥៨នាក់ ស្រី ៨២.៣១៨នាក់ ស្មើនឹង ៣៩.៣៨៧គ្រួសារ។

ខេត្តមានទំនប់វារីអគ្គិសនីមួយដែលមានអនុភាព ៤០០មេហ្គាវ៉ាត់ មានស្ពានឆ្លងកាត់ទន្លេចំនួន ៤កន្លែង ដែលស្ថិតនៅក្នុងទីរួមខេត្ត ២កន្លែង និងនៅផ្នែកខាងលើនៃទន្លេកុង ២កន្លែង។ មានផ្លូវជាតិសំខាន់ៗកាត់ខេត្តចំនួន ៣ គឺផ្លូវជាតិលេខ៧ លេខ៩ និងលេខ៧៨ សម្រាប់បម្រើការធ្វើចរាចរណ៍ភ្ជាប់មកកាន់រាជធានីភ្នំពេញ ប្រាសាទអង្គរវត្ត តំបន់មាត់សមុទ្រ និងទៅកាន់បណ្តាខេត្តផ្សេងៗទៀត។

## II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

### ❖ ក្រុមប្រឹក្សាខេត្ត

- កសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវបេតុ ផ្លូវកៅស៊ូ ផ្លូវក្រួសក្រហម ស្ពានបេតុង ស្ពានដែកបេឡេត៍ ការរៀបចំជម្រាលបេតុងការពារច្រាំងទន្លេក្នុងក្រុង និងមានការរៀបចំទីតាំងលំនៅដ្ឋានថ្មីសម្រាប់ប្រជាពលរដ្ឋដែលរស់នៅលើដីចំណីទន្លេក្នុងក្រុង ការពង្រឹងពង្រីកគុណភាពបរិមាណផលិតផលទេសចរណ៍តាមតំបន់សក្តានុពលទេសចរណ៍ក្នុងខេត្ត ការរៀបចំដីធ្លីលំនៅដ្ឋាន និងការឧបត្ថម្ភគាំទ្រជូនដល់គ្រួសារកងកម្លាំងការពារព្រំដែន។
- ការអនុវត្តវិធានការក្នុងការគ្រប់គ្រងថែរក្សាធនធានធម្មជាតិដីធ្លី ព្រៃឈើ ធនធានជលផល រ៉ែគ្រប់ប្រភេទ ការគ្រប់គ្រងនិងផ្តល់កម្មសិទ្ធិដីធ្លី តាមដានវាយតម្លៃផលប៉ះពាល់បរិស្ថាន ការបំពុលបរិស្ថាន គុណភាពទឹក គុណភាពខ្យល់ ការគ្រប់គ្រងផលប៉ះពាល់ពីគ្រោះមហន្តរាយ និងការលើកកម្ពស់ការយល់ដឹងអំពីការប្រតិបត្តិផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។
- ពង្រឹងនិរន្តរភាពការងារក្នុងប្រព័ន្ធរដ្ឋបាលមូលដ្ឋាន ការផ្តល់សេវារដ្ឋបាល និងសេវាសង្គម ការអនុវត្តផែនការសកម្មភាពក្នុងក្របខ័ណ្ឌគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ការបង្ក្រាប និងទប់ស្កាត់បទល្មើសគ្រប់ប្រភេទ និងការពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយខេត្ត នៃប្រទេសជាប់ព្រំដែន។
- រៀបចំកិច្ចប្រជុំដើម្បីធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ និងការតាមដានវាយតម្លៃការអនុវត្តសេចក្តីសម្រេច ជាកិច្ចប្រជុំសាមញ្ញមានចំនួន ២០លើក និងកិច្ចប្រជុំវិសាមញ្ញចំនួន ១០លើក។
- ធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ដោយបានដាក់ចេញនូវដីកា ស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា សម្រាប់អាណត្តិទី៣។

- រួមចំណែកការពង្រឹងអភិបាលកិច្ចល្អក្នុងការគ្រប់គ្រង ដឹកនាំការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងមូលដ្ឋាននៃដែនសមត្ថកិច្ចខេត្តស្ទឹងត្រែង តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានសមិទ្ធផលជារូបវន្ត និងអរូបវន្ត។
- បានពិនិត្យ និងអនុម័តលើក្របខ័ណ្ឌអភិវឌ្ឍន៍ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេល៥ឆ្នាំ តាមរយៈការសម្រេចដាក់ចេញនូវផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ ២០២០-២០២៤ សម្រាប់អាណត្តិទី៣ ក្រុមប្រឹក្សាខេត្ត។
- បានពិនិត្យ និងអនុម័តសម្រេចដាក់ចេញនូវកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្នុងឆ្នាំនីមួយៗ ដើម្បីបំលែងផែនការអភិវឌ្ឍន៍ខេត្ត ទៅជាគម្រោង និងសកម្មភាពអភិវឌ្ឍន៍ជាក់ស្តែង។
- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្រុមប្រឹក្សាខេត្ត បានកំណត់ក្នុងច្បាប់លិខិតបទដ្ឋានគតិយុត្ត ហើយបានរៀបចំក្របវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សា ប្រចាំឆ្នាំ និងបានផ្តល់ឱកាសឱ្យមានការចូលរួមផ្តល់យល់ លើកឡើងជាសំណើ សំណូមពរ និងកង្វល់មួយចំនួនទៀតដោយផ្ទាល់ពីប្រជាពលរដ្ឋ។
- អនុវត្តយុទ្ធនាការអប់រំផ្សព្វផ្សាយ ចលនាប្រជាជនចូលរួមក្នុងការលើកកម្ពស់អនាម័យ ថែរក្សាសុខភាពផ្ទាល់ខ្លួន គ្រួសារ សហគមន៍ និងបង្ការ ទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ ការគ្រប់គ្រងចលនាចូល-ចេញរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានភូមិសាស្ត្រខេត្ត និងវិធានការចត្តាឡីស័កតាមការណែនាំរបស់ក្រសួងសុខាភិបាល។

❖ **ក្រុងស្ទឹងត្រែង**

- បានស្ថាបនាប្រាំងទន្លេសេកុងប្រវែង ១៤០ម៉ែត្រ, ស្ថាបនាផ្លូវបេតុងឆ្អឹងដែកចំនួន ០៦ ខ្សែ, ផ្លូវកៅស៊ូ DBST ចំនួន០១ខ្សែ និងជួសជុលស្ពានដែកបេឡេ ០២កន្លែង។
- បានរៀបចំសណ្តាប់ធ្នាប់ ធ្វើឱ្យមានសោភ័ណ្ឌភាពតាមដងទន្លេ និងបានរៀបចំប្រជាជនដែលរស់នៅតាមជួរប្រាំងមាត់ទន្លេ ទទួលបាននូវដីជាកម្មសិទ្ធ និងអាស្រ័យផលសម្រាប់តាំងលំនៅថ្មី។
- បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅក្នុងក្រុង អំពីវិធានការបង្ការជំងឺកូវីដ១៩ និងធ្វើចត្តាឡីស័ក ចំពោះពលករ ឬអ្នកទើបត្រឡប់មកពីក្រៅប្រទេស។ និងបានអនុវត្តកម្មវិធីផ្តល់សាច់ប្រាក់ជូនគ្រួសារក្រីក្រក្នុងអំឡុងពេលកូវីដ១៩។

- បានចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបានចំនួន ១១ភូមិ និងបានបង្កើតក្រុមការងារថ្នាក់ខេត្តដើម្បីចុះសិក្សា កំណត់ព្រំប្រទល់ បោះបង្គោលព្រំផ្ទៃបឹង និងចុះបញ្ជីទីតាំងបឹងប្រវត្តិសាស្ត្រចំនួន ៣បឹង។

❖ **សង្កាត់ស្ទឹងត្រែង**

- សម្រេចបានគម្រោងសាងសង់ផ្លូវបេតុងអាមេចំនួន ០៣ ខ្សែ សរុបប្រវែង ៦៦៦ ម៉ែត្រ ទទឹង ៥ ម៉ែត្រ កម្រាស់ ១៥០ មម ចំណាយថវិកាសរុបចំនួន ២១៧.៧៣០.០០០ រៀល ជាគម្រោងអាទិភាពដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋសម្រួលបាននូវការធ្វើដំណើរ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។
- បានកសាងនូវផ្លូវបេតុងសសៃដែក , ផ្លូវDBST , រៀបចំប្រព័ន្ធលូក្នុងក្រុង ក្នុងភូមិសាស្ត្រសង្កាត់ជាច្រើនខ្សែប្រកបដោយគុណភាព ព្រមទាំងបានកសាងច្រាំងទន្លេ រង្វង់មូល រូបសំណាក់ និងសំណង់អាគាររដ្ឋបាលប្រកបដោយសោភ័ណ្ឌភាព និងសេចក្ដីថ្លៃថ្នូរ។
- ក្រុមប្រឹក្សាសង្កាត់ ក៏បានចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមភូមិ អំពីវិធានការណ៍បង្ការការចម្លងជំងឺកូវីដ-១៩ និងការធ្វើចត្តាឡីស័កចំនួន ១៤ ថ្ងៃ ចំពោះពលករ ឬ អ្នកទើបត្រឡប់ពីក្រៅប្រទេស ដែលបានធ្វើតេស្តកំហាក្សចហើយ។
- បានរៀបចំដោះដូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋចំនួន ១៣៩គ្រួសារ ដែលរស់នៅអាណាធិបតេយ្យ តាមមាត់ទន្លេសេកុង និងដោះស្រាយបានបញ្ហាការចោលសំរាមតាមទីសាធារណៈ និងបានរៀបចំឱ្យមានធុងសំរាមតាមសួនច្បារ ផ្សារ សាលារៀន និងតាមទីសាធារណៈនានា។

## III. ទិសដៅការងារបន្ត

❖ **ក្រុមប្រឹក្សាខេត្ត**

- ខិតខំចូលរួមចំណែកក្នុងសកម្មភាពធានារក្សាបានសុខសន្តិភាព សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឱ្យបានរឹងមាំ ជានាការពារប្រក្រតីភាពនៃស្ថាប័ន មន្ទីរ អង្គភាពជុំវិញខេត្ត រដ្ឋបាលមូលដ្ឋានក្រុង ស្រុក និងឃុំ សង្កាត់ និងការពង្រឹងចំណងសាមគ្គីភាព មិត្តភាពជាមួយបណ្ដាខេត្តជាប់ព្រំដែន និងមានភូមិផងរបងជាមួយគ្នា។
- ចូលរួមក្នុងការពិនិត្យ និងដោះស្រាយសំណើ សំណូមពរ បញ្ហាប្រឈម និងកង្វល់នានាដែលប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានបានស្នើឡើងស្របតាមច្បាប់ គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្ត។

- ជំរុញការតាមដាន វាយតម្លៃការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដែលបានដាក់ចេញក្នុងពេលកន្លងមក ពិសេសការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ដែលបានសម្រេចដាក់ចេញសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងខេត្ត។
- បន្តប្រាស្រ័យ ទំនាក់ទំនងជាមួយយន្តការរបស់ក្រុមប្រឹក្សា និងប្រជាពលរដ្ឋ ដើម្បីមានមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ បានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៅជាធរមាន។
- អនុវត្តកម្មវិធីប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាដែលបានកំណត់ក្នុងប្រតិទិនប្រជុំ និងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ព្រមទាំងច្បាប់ លិខិតបទដ្ឋានគតិយុត្តិ។
- បន្តរៀបចំផែនការសម្រាប់ធ្វើវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សានៅតាមមូលដ្ឋានក្រុង ស្រុកទាំង៦ ក្នុងអំឡុងត្រីមាសទី៤ នៃឆ្នាំនីមួយៗ។

❖ **ក្រុងស្ទឹងត្រែង៖**

- គម្រោងសាងសង់ផ្លូវអាមេប្រវែង ១៩៤ម៉ែត្រ ទទឹង ៧ម៉ែត្រ ស្ថិតនៅក្រុងស្ទឹងត្រែង
- បន្តការគាំទ្រ និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់ផ្នែកសុខុមាលភាពសហគមន៍ និងការផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋអំពីវិធានការបង្ការការចម្លងជំងឺកូវីដ១៩ នៅក្នុងសហគមន៍
- បន្តចុះផ្សព្វផ្សាយ និងបំផុសស្មារតីឱ្យប្រជាពលរដ្ឋចេះស្រឡាញ់បរិស្ថាន និងចូលរួមថែរក្សាធនធានធម្មជាតិ
- បន្តការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព និងបន្តការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋតាមតម្រូវការ និងតាមសំណូមពរ ប្រកបដោយប្រសិទ្ធភាព។

❖ **សង្កាត់ស្ទឹងត្រែង៖**

- បន្តការចុះសម្ភាសន៍គ្រួសារក្រីក្រតាមការស្នើសុំក្នុងអំឡុងពេលកូវីដ-១៩ និងការប្រមូលទិន្នន័យជនពិការសម្រាប់ការកំណត់អត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ។
- បន្តការយកចិត្តទុកដាក់ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីអនាម័យ បរិស្ថាននិងការចូលរួមវេចខ្ចប់ ការទុកដាក់សំរាមឱ្យមានរបៀប។ បំផុសស្មារតីប្រជាពលរដ្ឋឱ្យចេះស្រឡាញ់បរិស្ថាន និងការចូលរួមថែ រក្សាធនធានធម្មជាតិ។

- បន្តការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព និងបន្តការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋតាមតម្រូវការ និងតាមសំណូមពរ ប្រកបដោយប្រសិទ្ធភាព។ បន្តការយកចិត្តទុកដាក់ដោះស្រាយបញ្ហាប្រឈមនានានិង បញ្ហាទំនាស់ជូនប្រជាពលរដ្ឋក្រៅប្រព័ន្ធតុលាការ ។
- យកចិត្តទុកដាក់ចុះបញ្ជីអត្រានុកូលដ្ឋាន ជូនប្រជាពលរដ្ឋឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ ពង្រឹងការចុះឈ្មោះស្នាក់នៅបណ្តោះអាសន្ន និងជំរុញការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅជូនប្រជាពលរដ្ឋដោយមិនគិតថ្លៃសេវា ។

## IV. សម្គាល់

- ចំពោះស្ថានភាពព្រំដែនកម្ពុជា-ឡាវនាពេលបច្ចុប្បន្ន គឺមិនទាន់បើកដំណើរការនៅឡើយទេ ប៉ុន្តែចំពោះករណីចាំបាច់ដែលតម្រូវឱ្យមានការចេញ-ចូលប្រទេស គឺត្រូវអនុវត្តតាមគោលការណ៍របស់ក្រសួងសុខាភិបាល គឺត្រូវធ្វើចត្តាឡីស័ក និងរង់ចាំលទ្ធផលតេស្តអវិជ្ជមានកូវីដ-១៩។
- តាមរយៈកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ផែនការអភិវឌ្ឍន៍ខេត្ត ការទាក់ទាញវិនិយោគពីក្រៅប្រទេស និងការបើកវគ្គបណ្តុះបណ្តាលប្រជាពលរដ្ឋ អប់រំទៅលើបច្ចេកទេសដើម្បីលើកកម្ពស់ភាពមានការងារធ្វើ និងចូលរួមចំណែកកាត់បន្ថយអត្រាភាពក្រីក្ររបស់ប្រជាពលរដ្ឋ៕

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១